UNITED NATIONS
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

# សេចក្តីថ្លែងការណ៍
# របស់លោកតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ
# ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

**១៦ ឧសភា ២០០៣**

**លោកតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាមានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង ចំពោះឃាតកម្មកាលពីពេលថ្មីៗនេះ ដែលធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធតុលាការកម្ពុជា ។**

ឃាតកម្មលើចៅក្រម សុខ សេដ្ឋាមុនី នៃតុលាការរាជធានីភ្នំពេញនៅថ្ងៃទី ២៣ ខែមេសា និងលើក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ឈឹម ដារ៉ា នៅថ្ងៃទី ១០ ខែមេសានេះ មិនមែនត្រឹមតែជាឧក្រិដ្ឋកម្មដ៏គួរឱ្យស្អប់ខ្ពើមប៉ុណ្ណោះទេ តែវាក៏អាចធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំដើម្បីស្ថាបនាឡើងនូវតុលាការមួយខ្លាំង និងឯករាជ្យនៅក្នុងប្រទេសកម្ពុជាដែរ ។ ចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិកតុលាការ មិនអាចធ្វើការបានដោយប្រសិទ្ធភាព ឬអាចទុកចិត្តបានទេ បើពួកគេជាកម្មវត្ថុនៃការវាយប្រហារដោយនិទ្ទណ្ឌភាព ។

លោកតំណាងពិសេស សូមអំពាវនាវដល់អាជ្ញាធរកម្ពុជាឱ្យធ្វើការស៊ើបអង្កេតដោយហ្មត់ចត់ និងមិនលំអៀង ទៅលើឃាតកម្មទាំងនេះ និងផ្តន្ទាទោសជាបន្ទាន់ចំពោះជនល្មើស និងអ្នកដែលបញ្ជាពួកគេ ។

លោកកត់សំគាល់អំពីការចាប់ខ្លួនថ្មីៗក្នុងករណីសម្លាប់លោក ឈឹម ដារ៉ា ហើយសង្ឃឹមថាការផ្តន្ទាទោសចំពោះករណីទាំងពីរនេះ នឹងប្រព្រឹត្តទៅប្រកបដោយតម្លាភាពពេញលេញ និងស្របទាំងស្រុងទៅនឹង ច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ។

#16A, Mao Tse Tuong Blvd, Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១៦A មហាវិថី ម៉ៅ សេទុង សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧